នស/រកត/០៩១៣/៩០៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/ ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់សេចក្តីសម្រេចលេខ ៤៦៥/១៣ គ.ជ.ប.សសរ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការប្រកាសលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ថ្ងៃអាទិត្យ ទី ២៨ ខែ កក្កដា ឆ្នាំ ២០១៣
- បានទ្រង់យល់សំណើរបស់គណបក្សប្រជាជនកម្ពុជា លេខ ៨៨៤ លគ.គក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ព្រឹទ្ធសមាជិករដ្ឋសភា នីតិកាលទី៥

## ត្រាស់បង្គាប់

**មាត្រា ១ :** ចាត់តាំង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជា **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចរៀបចំសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសុំសេចក្តីអនុម័តទុកចិត្តពីរដ្ឋសភា។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពាន. ១៣០៩.៩១៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣*

លេខ: ៧៥៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែ កញ្ញា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**ស៊យ សុខា**